# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងអភិវឌ្ឍន៍ជនបទ**

លេខ : ០៧១៥/១០ ក.អ.ជ

រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១០.

## រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ

## ជម្រាបមក

## លោក ផ្លង ចាវ៉ាន់ តំណាងសហគមន៍ជនជាតិដើមភាគតិច គ្រឹង ភូមិក្រេះ ឃុំប៉ូយ ស្រុកអូរជុំ

**កម្មវត្ថុ:** ស្តីពីការទទួលស្គាល់អត្តសញ្ញាណសហគមន៍ជនជាតិដើមភាគតិច គ្រឹង ភូមិក្រេះ ឃុំប៉ូយ ស្រុកអូរជុំ

**យោង:**
- លិខិតចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ២០០៩ ស្តីពីការស្នើសុំទទួលស្គាល់អត្តសញ្ញាណសហគមន៍ជនជាតិដើមភាគតិច គ្រឹង ភូមិក្រេះ របស់លោក ផ្លង ចាវ៉ាន់ តំណាងសហគមន៍។
- លិខិតលេខ ១៨៤/១០ ល.អ.ខ ចុះថ្ងៃទី ២៣ ខែ មេសា ឆ្នាំ២០១០ ស្តីពីការទទួលស្គាល់អត្តសញ្ញាណសហគមន៍ជនជាតិដើមភាគតិច គ្រឹង ភូមិក្រេះ របស់អភិបាល នៃគណៈអភិបាលខេត្តរតនគិរី។
- លទ្ធផលវាយតម្លៃអត្តសញ្ញាណសហគមន៍ជនជាតិដើមភាគតិច គ្រឹង ភូមិក្រេះ របស់ក្រុមការងារនាយកដ្ឋានអភិវឌ្ឍន៍ជនជាតិភាគតិច នៃក្រសួងអភិវឌ្ឍន៍ជនបទ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ សូមលោកជ្រាបថា ក្រសួងអភិវឌ្ឍន៍ជនបទយល់ព្រមទទួលស្គាល់អត្តសញ្ញាណសហគមន៍ជនជាតិដើមភាគតិច គ្រឹង ភូមិក្រេះ ឃុំប៉ូយ ស្រុកអូរជុំ ខេត្តរតនៈគិរី តាមសំណើ។ សហគមន៍ជនជាតិដើមភាគតិច គ្រឹង ភូមិក្រេះ អាចប្រើប្រាស់លិខិតទទួលស្គាល់អត្តសញ្ញាណនេះ ក្នុងសកម្មភាពបម្រើដល់ផលប្រយោជន៍រួមរបស់សហគមន៍ ផលប្រយោជន៍សង្គម និងផលប្រយោជន៍ជាតិ តាមការចាំបាច់ស្របតាមគោលនយោបាយ ច្បាប់ បទបញ្ញា និងលិខិតបទដ្ឋានទាំងឡាយ នៃព្រះរាជាណាចក្រកម្ពុជា។

សូមលោក ទទួលនូវសេចក្តីស្រឡាញ់រាប់អានដ៏ជ្រាលជ្រៅពីខ្ញុំ។

ព្រះរាជាណាចក្រកម្ពុជា
ក្រសួងអភិវឌ្ឍន៍ជនបទ

ជា សុផារ៉ា

*ចម្លងជូន*

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងទេសចរណ៍
  "ដើម្បីជូនជ្រាប"
- សាលាខេត្តរតនគិរី
- មន្ទីរអភិវឌ្ឍន៍ជនបទខេត្តរតនគិរី
  "ដើម្បីមុខការ"
- ឯកសារកាលប្បវត្តិ

អាសយដ្ឋាន កាច់ជ្រុងផ្លូវលេខ 169 និងមហាវិថីសហព័ន្ធរុស្ស៊ី រាជធានីភ្នំពេញ ទូរស័ព្ទ (855) 23 884 539
ទូរសារ (855) 23 991 117 ប្រអប់សំបុត្រ 2016 គេហទំព័រ www.mrd.gov.kh អ៊ីមែល mrd.cabinet@gmail.com